**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៧ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូចំការអណ្ដូង

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ ជស/រកម/ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពី ការអនុវត្តន៍ព្រះរាជក្រម ស្ដីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០០៣ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

-បានឃើញកិច្ចសន្យាទិញ-លក់ និង កិច្ចសន្យាជួលដី ចុះថ្ងៃទី ០៣ ខែ មេសាឆ្នាំ ២០០៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុន អាន ម៉ាឌី គ្រុប

-តាមសំណើរបស់គណៈកម្មាធិការជាតិអវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

# ស ម្រេ ច

**មាត្រា ១**:បញ្ចប់ស្ថានភាពគតិយុត្តិចំការកៅស៊ូចំការអណ្តូងដែលជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ចាប់ពីថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ តទៅ។

**មាត្រា ២** :ផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូចំការអណ្តូង ទៅឱ្យក្រុមហ៊ុន អាន ម៉ាឌី គ្រុប (AN MADY Group Co., Ltd.)ដើម្បីបន្តគ្រប់គ្រងស្របតាមបទប្បញ្ញត្តិនានាដែលបានកំណត់ក្នុងកិច្ចសន្យាទិញ-លក់ និងកិច្ចសន្យាជួលដី ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រុមហ៊ុន អាន ម៉ាឌី គ្រុប (AN MADY Group Co., Ltd.) ចាប់ពីថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ តទៅ។

**មាត្រា ៣** : រំសាយក្រុមប្រឹក្សាភិបាលប្រចាំចំការកៅស៊ូចំការអណ្តូង ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យលេខ ៨៥១ អនក្រ-តត ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៥ ត្រង់ ចំណុច ច នៃមាត្រា១ រំសាយប្រធានអគ្គនាយកចំការកៅស៊ូចំការអណ្តូង និង រំសាយមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូចំការអណ្តូង ចាប់ពីថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ តទៅ។

**មាត្រា ៤** : ផ្ទេរឯកឧត្តម លឹម ស៊ុនលាង ប្រធានអគ្គនាយកចំការកៅស៊ូចំការអណ្តូង ចូលមកបំរើការងារក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទវិញ ចាប់ពីថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ តទៅ។

**មាត្រា ៥**: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកដោះស្រាយបន្ត រាល់បំណុលត្រូវទារ និង ត្រូវសង ដែលនៅសេសសល់ទាំងអស់ រវាងចំការកៅស៊ូចំការអណ្តូង និងបណ្តាក្រុមហ៊ុន ស្ថាប័ននានា និង អតិថិជន និងបន្តស្រាវជ្រាវ និងប្រមូលចំណូលបានពីការកាប់ដើមកៅស៊ូចាស់ៗដែលមិនត្រូវបានយកទៅប្រើប្រាស់សំរាប់ការដាំដុះឡើងវិញ ដើម្បីបង់ចូលថវិការដ្ឋ។

**មាត្រា ៦**: ចំការកៅស៊ូចំការអណ្តូង ត្រូវប្រគល់ត្រា និងឯកសារពាក់ព័ន្ធទាំងអស់ រួមទាំងឯកសារក្នុងកុំព្យូទ័រ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីរក្សាទុក។

**មាត្រា ៧** : ថវិកាដែលនៅសល់ក្នុងគណនី និង បេឡា របស់ចំការកៅស៊ូចំការអណ្តូង ត្រូវផ្ទេរចូលថវិការដ្ឋ។ បិទរាល់គណនីធនាគារទាំងអស់របស់ចំការកៅស៊ូចំការអណ្តូង ចាប់ពីថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ តទៅ។

**មាត្រា ៨** : អនុក្រឹត្យលេខ ១៨ អនក្រ-បក ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតចំការកៅស៊ូ ចំការអណ្តូង ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ចាប់ពីថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ តទៅ។

**មាត្រា ៩** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមានក្នុងមាត្រា ៩
- ឯកសារ-កាលប្បវត្តិ